ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស
លេខ: ០០២/១៧ សរព.ពបព

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
# ថ្ងៃសុក្រ ទី ២៤ ខែ មីនា ឆ្នាំ ២០១៧

នៅព្រឹកថ្ងៃសុក្រទី២៤ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង៨ និង៣០នាទី នៅវិមានសន្តិភាព មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៥ ដើម្បីឆ្លង៖

**១- សេចក្តីព្រាងច្បាប់ស្តីពីឧបាស្រ័យពាណិជ្ជកម្ម។**

**២- សេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥។**

**៣- បញ្ហាផ្សេងៗ។**

ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចអនុម័ត៖

## ១- សេចក្តីព្រាងច្បាប់ស្តីពីឧបាស្រ័យពាណិជ្ជកម្ម។

សេចក្តីព្រាងច្បាប់ស្តីពីឧបាស្រ័យពាណិជ្ជកម្ម រៀបចំឡើងដោយក្រសួងពាណិជ្ជកម្ម មានគោលបំណងការពារ និងដោះស្រាយផលប៉ះពាល់ជាអវិជ្ជមានចំពោះឧស្សាហកម្មកម្ពុជា បណ្តាលមកពីការធ្វើពាណិជ្ជកម្មនាំចូលដោយមិនស្មោះត្រង់ និងការនាំចូលដោយគំហុក ដោយប្រើប្រាស់វិធានការឧបាស្រ័យពាណិជ្ជកម្ម អនុលោមតាមកិច្ចព្រមព្រៀងពាក់ព័ន្ធរបស់អង្គការពាណិជ្ជកម្មពិភពលោក។

សេចក្តីព្រាងច្បាប់នេះមាន៦ជំពូក និង៤៨មាត្រា មានវិសាលភាពអនុវត្តចំពោះការលក់បង្ខូចថ្លៃ ការឧបត្ថម្ភធន និងវិធានការពន្ធប៉ះប៉ូវ និងវិធានការការពារទាក់ទងនឹងការធ្វើពាណិជ្ជកម្មក្នុងព្រះរាជាណាចក្រកម្ពុជា អនុលោមតាមកិច្ចព្រមព្រៀងពាក់ព័ន្ធរបស់អង្គការពាណិជ្ជកម្មពិភពលោក។



ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៤១ មហាវិថីសហព័ន្ធរុស្ស៊ី
ទូរសារលេខ: ០២៣ ២១២ ៤៩០, ទូរស័ព្ទ: ០១២ ៥៥៥ ៩៣៦, ០៩៧ ៧ ៩៩០ ៦០៨
អ៊ីមែល: pressocm@gmail.com

## ២- សេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥។

ក្នុងរយៈពេល ២ទសវត្សរ៍ចុងក្រោយនេះបន្ទាប់ពីព្រះរាជាណាចក្រកម្ពុជាទទួលបានសុខសន្តិភាព ពេញលេញទូទាំងប្រទេសនៅឆ្នាំ ១៩៩៨ដោយសារនយោបាយឈ្នះ-ឈ្នះ របស់សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រី អត្រាកំណើនសេដ្ឋកិច្ចមធ្យមប្រចាំឆ្នាំមានកម្រិតប្រមាណ៧.៧ ភាគរយហើយអត្រាកំណើន ដ៏គួរជាទីមោទនៈនេះត្រូវបានរំពឹងថា នឹងរក្សាសន្ទុះបន្តទៀតសម្រាប់រយៈពេលមធ្យមខាងមុខ។ អត្រាភាពក្រីក្របានកាត់បន្ថយពី៥៣ភាគរយ នៅឆ្នាំ២០០៤ មក១៣.៥ភាគរយនៅឆ្នាំ ២០១៤។ លើសពីនេះទៀត ផ្លែផ្កានៃកំណើនសេដ្ឋកិច្ចត្រូវបានបែងចែកក្នុងលក្ខណៈកាន់តែមានសមធម៌ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈការថយចុះនៃមេគុណវិសមភាពនៃការប្រើប្រាស់ពី ០.៤១ នៅឆ្នាំ២០០៧ មកនៅត្រឹម០.២៩ នៅឆ្នាំ២០១២ ជាមួយនឹងការរំពឹងថាតួលេខនេះនឹងបន្តថយចុះថែមទៀតនៅឆ្នាំខាងមុខ។ សមិទ្ធផលទាំងនេះគឺជាការពិតដែលមិនអាចបដិសេធបាន និងជាមោទនភាពសម្រាប់រាជរដ្ឋាភិបាលនិងប្រជាជនកម្ពុជា។

កន្លងមក រាជរដ្ឋាភិបាលតែងផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមដែលស្តែងចេញពីការដាក់ឲ្យដំណើរការបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស) បេឡាជាតិអតីតយុទ្ធជន (ប.ជ.អ) និងមូលនិធិជនពិការ (ម.ជ.ព) ព្រមទាំងការអនុម័តយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងងាយរងគ្រោះ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការដាក់ឲ្យដំណើរការកម្មវិធីជាតិជំនួយសង្គមមួយចំនួន។ សម្រាប់អាណត្តិទី៥នេះ រាជរដ្ឋាភិបាលបានដាក់ចេញគោលនយោបាយកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យក្នុងនោះយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ បានកំណត់យក«ការបន្តពង្រឹង និងអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឲ្យមានលក្ខណៈប្រមូលផ្តុំ សង្គតិភាព និងប្រសិទ្ធភាព» ជាគោលដៅអាទិភាព។

គោលនយោបាយជាតិគាំពារសង្គម២០១៦-២០២៥ ដែលដឹកនាំរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានគោលដៅជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឲ្យកាន់តែរឹងមាំ និងល្អប្រសើរឡើងព្រមទាំងអាចគ្របដណ្តប់ប្រជាជនគ្រប់រូប ជាពិសេសប្រជាជនក្រីក្រ និងងាយរងគ្រោះ។

ចក្ខុវិស័យរយៈកាលវែងរបស់រាជរដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម គឺការកសាងប្រព័ន្ធគាំពារសង្គមប្រកបដោយបរិយាប័ន្ន ប្រសិទ្ធភាព និងចីរភាពហិរញ្ញវត្ថុ ដែលជាឧបករណ៍បម្រើដល់ការកាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព

ហើយរួមចំណែកដល់ការអភិវឌ្ឍ និងគាំពារធនធានមនុស្សកាន់តែទូលំទូលាយ និងជំរុញកំណើនសេដ្ឋកិច្ច។

**៣- បញ្ហាផ្សេងៗ៖**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ជូនពរដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ប្រជាពលរដ្ឋកម្ពុជា ទាំងក្នុង និងក្រៅប្រទេស ឲ្យទទួលបានសុខភាពល្អ មានសុវត្ថិភាពក្នុងការធ្វើដំណើរ និងសប្បាយរីករាយ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិឆ្នាំរការ នព្វស័ក ពុទ្ធសករាជ២៥៦១ គ.ស ២០១៧នេះ។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង ១០និង ២០នាទី ព្រឹក

រាជធានីភ្នំពេញ, ថ្ងៃសុក្រ ទី២៨ ខែមីនា ឆ្នាំ២០១៧